ទំនុកដំកើង១៣៧:១-៩

ជំពូក ១៣៧

***ជាតិចនា** ច្រៀងបទថ្វាយព្រះក្នុងផ្ទះអ្នកដទៃ*

ការសិក្សាព្រះគម្ពីរទំនុកដំកើង ប្រៀបឧបមាដូចជាការធ្វើដំណើរតាមរថយន្ត ទៅលេងស្រុកឆ្ងាយ។ នៅពេលធ្វើដំណើរ ជួនកាលយើងឃើញទិដ្ឋភាពគួរអោយពិត ពិលរមិលមើល ជួនកាលឃើញទិដ្ឋភាពដែលភ្នែកយើងមិនជឿថា មានហេតុអាក្រក់បែប នោះកើតឡើងនៅលើលោកនេះ។ ក្នុងគម្ពីរទំនុកដំកើង មានជំពូកខ្លះជាទីរីករាយ សប្បាយ ជំពូកខ្លះជាការលើកទឹកចិត្ត ជំពូកខ្លះមើលទៅហាក់ដូចជាតប់ប្រមល់ ឯជំពូក ខ្លះទៀតមើលទៅមិនយល់សោះតែម្តង។ ជំពូក១៣៧ត្រូវនឹងករណីចុងក្រោយ គឺពិបាក យល់យ៉ាងក្រៃលែង។ ប៉ុន្តែ សូមជ្រាបថា គម្ពីរទំនុកដំកើងជំពូក១៣៧ជាព្រះបន្ទូលរបស់ ព្រះជាម្ចាស់។ តើព្រះជាម្ចាស់មានអ្វីបង្កប់ទុកនៅក្នុងជំពូក១៣៧នេះ? ដោយសារជំពូក ១៣៧មានការពិបាកយល់ យើងចាំបាច់ត្រូវឈប់មើល ពីរត្រូវឈរពិនិត្យ និងបីត្រូវ ឈានដំណើរ។ ដំបូងបង្អស់យើងត្រូវឈប់ ដើម្បីពិចារណាមើលខ្លឹមសារក្នុងជំពូក ១៣៧។ ជំពូក១៣៧បរិយាយពីសេចក្តីអធិស្ឋានដាក់បណ្តាសា។ ព្រះបន្ទូលព្រះជាម្ចាស់ អនុញ្ញាតិ ជនជាតិអ៊ីស្រាអែលអធិស្ឋានដាក់បណ្តាសា។ ផ្ទុយស្រឡះ គ្រីស្ទបរិស័ទគ្មាន

សិទ្ធិប្រើសេចក្តីអធិស្ឋានប្រភេទនោះទេ។ សេចក្តីអធិស្ឋានដាក់បណ្តាសាមានដូចជា ខ៩ដែលថែងថា "សប្បាយហើយ អ្នកណាដែលនឹងចាប់កូនតូចរបស់ឯង ទៅបោកនឹងថ្ម..."។ តើឃ្លានេះមានន័យដូចម្តេច? បើពិចារយល់បែបនេះ តើយើងគួរវិលឯខមួយនេះទៅឬ? ពេលជួបនិងអត្ថបទពិចារយល់ អ្នកខ្លះផ្លោះទៅកន្លែងដែលស្រួលយល់។ បើធ្វើបែបនេះ យើងរកតែព្រះបន្ទូលណាដែលអាចអេះត្រចៀករមាស់របស់យើងប៉ុណ្ណោះ។ ពេលសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ សិក្ខាកាមតែងមានប្រតិកម្មបីយ៉ាង។

ខ្លះមិនរាប់ជំពូកឬខណាដែលពិចារក ថាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គេស្រង់យកតែបទគម្ពីរណាល្អៗមកអនុវត្ត។ បទគម្ពីរណាដែលពិចារយល់ គេចោះចោលតែម្តង។ គេយល់ថា ព្រះបន្ទូលសម្តែងសម្រាប់គាំទ្រសេចក្តីល្អរបស់គេ។ ឯអំពើចាបរបស់គេវិញ គេលាក់អោយជិត។ ការស្រង់យកព្រះបន្ទូលកន្លែងណាល្អយកមកអនុវត្ត កន្លែងណាមិនល្អចោះចោល ប្រៀបឧបមាដូចជាបុរសម្នាក់ទិញមេគោមួយ។ គាត់ទិញមេគោមួយ ព្រោះគាត់សង្ឃឹមចង់បានកូនពីមេគោនោះ។ គាត់យកចិត្តទុកដាក់ចង់បានកូនរបស់មេគោ តែគាត់មិនយកចិត្តទុកដាក់នឹងមេគោឡើយ។ មួយថ្ងៃៗគាត់ដេកសង្ឃឹមថា មេគោនឹងបង្កើតកូនអោយគាត់។ បុរសនោះភ្លេចយកមេគោទៅថែទាំអោយបានល្អ។ ទីបំផុតមេគោក៏ស្លាប់បាត់ទៅ។ ការសង្ឃឹមរបស់គាត់ បែរជាមិនបានសម្រេចពីព្រោះគាត់មិនបានចំណាយពេល ចំណាយលុយ ចំណាយកម្លាំង ដើម្បីថែទាំមេគោនោះអោយមានសុខភាពល្អ។ ការច្បិចយកខគម្ពីរល្អៗមកអនុវត្ត ខណាមិនល្អកៀស

ចោល ញ៉ាំងអោយខាតបង់ប្រយោជន៍ដល់អ្នកសិក្សាព្រះបន្ទូលព្រះជាម្ចាស់ខ្លាំងណាស់។ ខ្លះទៀតជឿថា ព្រះបន្ទូលព្រះជាម្ចាស់ល្អ ពីក្របម្ខាងដល់ក្របម្ខាង។ ប៉ុន្តែគេមិនបានយល់ពីខ្លឹមសារព្រះបន្ទូលថានិយាយអ្វីខ្លះទេ។ ជនប្រភេទនោះក្បៀតព្រះគម្ពីរនៅក្រោមក្លៀក។ គេមិនយល់ថា ព្រះគម្ពីរនិយាយពីអ្វីសម្រាប់ជីវិតរបស់គេ។ ជនប្រភេទនោះត្រូវរាប់ថា ជាជនអវិជ្ជាផ្នែកព្រះបន្ទូលព្រះជាម្ចាស់។ គេស្រឡាញ់ព្រះបន្ទូល តែមិនចូលចិត្តសិក្សាព្រះបន្ទូល ពីព្រោះគេខ្លាចព្រះបន្ទូលកូតអំនួតចេញពីចិត្តរបស់គេ។

ឯជនប្រភេទទីបី សិក្សាព្រះបន្ទូលពីក្របម្ខាងដល់ក្របម្ខាង។ ជនជំពូកនេះសិក្សាព្រះបន្ទូលយ៉ាងលំអិតពីមួយខទៅមួយខ។ ការធ្វើរបៀបនេះ នាំមកនូវអត្ថប្រយោជន៍ សម្រាប់អ្នកសិក្សាព្រះបន្ទូលព្រះជាម្ចាស់សម្អាតព្រលឹង និងសំអាតអំពើបាបយើងជារៀងរាល់ថ្ងៃ។ ខ្ញុំរាប់ខ្លួនខ្ញុំថាជាជនប្រភេទជនទីបី។ ថ្វីដ្បិតគម្ពីរទំនុកជំកើងជំពូក១៣៧ ជាសេចក្តីអធិស្ឋានដាក់បណ្តាសា ជំពូកនេះមានសេចក្តីពិតសម្រាប់យើងយកមកអនុវត្ត។ តើជំពូក១៣៧មានអាថ៌កំបាំងអ្វីខ្លះបង្កប់សម្រាប់យើង?

ដើម្បីឆ្លើយនឹងសំណួរខាងលើ យើងចាំបាច់ត្រូវយកគោលការណ៍ទីពីរមកប្រើ។ គោលការណ៍ទីពីរ គឺឈរ។ គោលការណ៍ទីមួយ យើងត្រូវឈប់ដើម្បីពិចារណា។ គោលការណ៍ទីពីរ យើងត្រូវឈរដើម្បីពិនិត្យមើលអោយបានហ្មត់ចត់។ ក្នុងជំពូក១៣៧ ព្រះជាម្ចាស់បង្ហាញប្រវត្តិសាស្ត្ររបស់មនុស្សលោក ពិសេសប្រវត្តិសាស្ត្រាស្ត្រទ្រង់នៅសម័យពួកចាប៊ីឡូនកៀរយកសាសន៍អ៊ីស្រាអែលទៅធ្វើជាទាសករ។ នៅក្នុងព្រះគម្ពីរ

សញ្ញាចាស់ យើងមិនឃើញមានហេតុការណ៍ក្នុងប្រវត្តិសាស្ត្រ ដែលសាសន៍អ៊ីស្រាអែលត្រូវគេចាប់យកទៅធ្វើជាឈ្លើយ បង្ខំអោយធ្វើការយ៉ាងទម្ងន់ ទទួលការវាយដំ មើលងាយ មើលថោកពីសំណាក់អ្នកដែលចាប់ខ្លួនយកទៅទេ។ លោកយេរេមាគ្រាន់តែទាយពីជំណើរសាសន៍អ៊ីស្រាអែលត្រូវពួកបាប៊ីឡូនចាប់យកទៅធ្វើជាឈ្លើយ។ ហោរាអេសេគាលរស់នៅក្នុងអំឡុងពេលដែលលោកធ្វើជាឈ្លើយ។ ប៉ុន្តែ លោកមិនបានពណ៌នាអំពីស្ថានភាព ជាឈ្លើយនោះអោយបានច្បាស់លាស់ទេ។ ចំណែកហោរាដានីយ៉ែលវិញ លោករស់នៅក្នុងអំឡុងពេលសាសន៍អ៊ីស្រាអែលធ្វើជាឈ្លើយដែរ។ ប៉ុន្តែលោកជាអ្នកនយោបាយ។ លោកគិតគូរតែពីរឿងកើតឡើងនៅក្នុងផ្ទៃវាំងរបស់ប្រទេសបាប៊ីឡូន។ លោកមិនបានបរិយាយពីស្ថានភាពជាក់ស្តែងនៃសាសន៍អ៊ីស្រាអែល ដែលរស់នៅយ៉ាងវេទនា ក្រោមក្រញាំដៃដែករបស់សាសន៍បាប៊ីឡូនទេ។ យើងមានដំណឹងខ្លះស្តីពីជំនាន់នោះដែលបានកត់ត្រាទុកក្នុងគម្ពីរពង្សាវតារក្សត្រ។ ប៉ុន្តែ ព្រះគម្ពីទាំងពីរក្បាលនោះ រៀបរាប់ប្រវត្តិសាស្ត្រអ៊ីស្រាអែលត្រឹមដល់ពេល ត្រឹមគេបំផ្លាញទីក្រុងយេរូសាឡិមចោល។ ចំណែកព្រះគម្ពីរអែសរ៉ា នេហេមា នាងអេសធើរវិញ បរិយាយក្រោយគ្រាដែលសាសន៍អ៊ីស្រាអែល ធ្វើជាឈ្លើយសឹករបស់ពួកបាប៊ីឡូន។ កំពុងតែគ្មានឯកសារណា បញ្ជាក់អោយឃើញពីស្ថានភាពពិតប្រាកដរបស់សាសន៍អ៊ីស្រាអែលក្នុងគ្រាដែលខ្លួនធ្វើជាឈ្លើយសឹក ជំពូក១៣៧ចូលមកបំពេញតួនាទីនេះតែម្តង។ ជំពូកនេះបរិយាយពីស្ថានភាពរបស់សាសន៍អ៊ីស្រាអែល រស់ជាជនភៀសខ្លួននៅប្រទេសដទៃ។ ឥឡូវ យើងឃើញពន្លឺខ្លះ បន្ទាប់ពីយើងប្រើគោលការណ៍ទីពីរ។ គោលការណ៍ទីមួយគឺ

ឈប់ គោលការណ៍ទីពីរគឺឈរ។ រីឯគោលការណ៍ទីបី ក្នុងការសិក្សាព្រះបន្ទូល ត្រូវឈាន។ នៅពេលដែលយើងឈានដំណើរ យើងផ្ទៀងត្រចៀកស្តាប់ ដើម្បីស្តាប់ឮព្រះបន្ទូលព្រះជាម្ចាស់ ទ្រង់កំពុងតម្រង់ផ្លូវយើង។ ឥឡូវ យើងឮព្រះបន្ទូលព្រះអង្គនៅក្នុងជំពូក១៣៧:៤ថា "តើយើងនឹងច្រៀងបទនៃព្រះយេហូវ៉ា នៅក្នុងប្រទេសដទៃដូចម្តេចបាន?" ទោះបីឮព្រះបន្ទូលព្រះអង្គដូច្នេះហើយក៏ដោយ ខ្ញុំមិនដឹងថា ខ្ញុំមានសមត្ថភាពអាចឆ្លើយនឹងសំណួរនេះបានឬយ៉ាងណាទេ? យើងនឹងសិក្សាជាបន្តទៅទៀតថា តើសំណួរនេះត្រូវឆ្លើយបែបណា?

ទំនុកដំកើងជំពូក១៣៧ជាឯកសារ កត់ត្រាទុកនូវបទពិសោធន៍យ៉ាងល្វីងជូរចត់របស់សាសន៍អ៊ីស្រាអែល ពេលគេរស់នៅក្នុងចិតសិបឆ្នាំក្រោមនឹមដែករបស់ពួកបាប៊ីឡូន។ នៅក្នុងជំពូក១៣៧មានបរិយាយពីសេចក្តីសួបខ្ពើមយ៉ាងជូរចត់ និងសេចក្តីស្រឡាញ់ដ៏ផ្អែមល្ហែមក្នុងពេលតែមួយ។ យើងឃើញរាស្ត្ររបស់ព្រះជាម្ចាស់ មានមនោសញ្ចេតនាខ្ពស់ផង ទាបផង។ សូមយើងសិក្សាគម្ពីរទំនុកដំកើងជំពូក១៣៧ដែលជាព្រះបន្ទូលមានលក្ខណៈពិបាកយល់ដូចតទៅ :

បទពិសោធន៍ជាឧទ្ធេរ

យើងបានអង្គុយចុះ នៅមាត់ទន្លេស្រុកបាប៊ីឡូន អើ យើងបានយំ ដោយនឹករឭកដល់ក្រុងស៊ីយ៉ូន (ទំនុកដំកើង១៣៧:១)។

ដើម្បីអោយយល់ពីដំពូកនេះ យើងត្រូវយកទីកន្លែងដែលសាសន៍អ៊ីស្រាអែល កំពុងស្នាក់នៅមកពិចារណា។ ខ១សម្តែងថា "យើងបានអង្គុយចុះ នៅមាត់ទន្លេស្រុកបាប៊ីឡូន..."។ នៅក្នុងប្រវត្តិសាស្ត្រ សាសន៍អ៊ីស្រាអែលស្គាល់ភូមិសាស្ត្រពីស្រុកអេស៊ីព្ទ ទៅស្រុកបាប៊ីឡូនយ៉ាងច្បាស់លាស់។ នគរពិតប្រាកដរបស់គេ គឺអ៊ីស្រាអែល។ ប៉ុន្តែ នៅក្នុងប្រវត្តិសាស្ត្រ សាសន៍អ៊ីស្រាអែលធ្លាប់ធ្វើជាទាសករនៅប្រទេសអេស៊ីព្ទ។ ឥឡូវ នៅប្រទេសបាប៊ីឡូន គេធ្វើជាឈ្លួលកំដរបរបស់គេនៅទីនោះទៀត។ ប្រទេសអេស៊ីព្ទស្ថិត នៅចុងខាងត្បូងនៃឧបទ្វីបអារ៉ាប់។ រីឯប្រទេសបាប៊ីឡូនវិញ ស្ថិតនៅចុងខាងជើងនៃឧបទ្វីបនេះ។ នៅក្នុងស្រុកទាំងពីរនេះ សាសន៍អ៊ីស្រាអែលធ្វើជាខ្ញុំកំដរបរបស់គេ ព្រមទាំងទទួលការកៀបសង្កត់យ៉ាងខ្លាំងពីសំណាក់អ្នកគ្រប់គ្រងខ្លួន។

ហេតុអ្វីបានជាសាសន៍អ៊ីស្រាអែល បែរជាអង្គុយនៅមាត់ទន្លេស្រុកបាប៊ីឡូនទៅវិញ? សាសន៍នេះត្រូវស្នាក់នៅក្នុងទឹកដីសន្យា ដែលព្រះជាម្ចាស់ប្រទានអោយគេ។ ប៉ុន្តែគេបានប្រព្រឹត្តខុសនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ បានជាគេត្រូវមកអង្គុយនៅឯស្រុកបាប៊ីឡូនយ៉ាងវេទនាទៅវិញ។ តើគេអង្គុយនៅទីនោះធ្វើអ្វី? នៅចន្លោះទន្លេទីគ្រីស គ្រាសនិងទន្លេអ៊ើព្រាត សាសន៍បាប៊ីឡូននាំជនជាតិអ៊ីស្រាអែល អោយជីកព្រែកដើម្បីភ្ជាប់ទន្លេទាំងពីរ។ សាសន៍បាប៊ីឡូនពីងពាក់ទាំងស្រុងនៅលើផលិតផលកសិកម្ម ដើម្បីផ្គត់ផ្គង់ដល់សង្គ្រាមឈ្លានពានរបស់ខ្លួន។ ដូច្នេះដើម្បីធ្វើអោយមានផលស្រូវច្រើន គេចាំបាច់ត្រូវយកទឹកទន្លេដើម្បីស្រោចស្រប់លើដីសណ្ត ដែលស្ថិតនៅចន្លោះទន្លេទាំងពីរ។ សាសន៍អ៊ីស្រាអែល ត្រូវជីកព្រែកនោះទាំងយប់ទាំងថ្ងៃ ដោយគេវាយបង្ខំ

អោយធ្វើការយ៉ាងទម្ងន់។ គេត្រូវព្រាត់ប្រាស់កូនចៅ។ គេរៀបជាក្រុមបុរស ក្រុមស្ត្រី ក្រុមកុមារ ក្រុមយុវជន អោយនៅដាច់ដោយឡែក។ពីគ្នាអស់រយៈពេលចិតសិបឆ្នាំ។ ដោយហេតុនោះហើយបានជាសាសន៍អ៊ីស្រាអែល នាំគ្នាអង្គុយចុះនៅមាត់ទន្លេស្រុកបាប៊ីឡូន ហើយពោលថា "អើ យើងបានយំដោយនឹករឭកដល់ក្រុងស៊ីយ៉ូន"។ សាសន៍អ៊ីស្រាអែលយំនឹកស្រុក កំពុងតែគេបង្ខំអោយធ្វើការយ៉ាងទម្ងន់នៅក្នុងភូមិស្រុកអ្នកដទៃ។ នៅក្នុងគម្ពីរទំនុកដំកើង ទីក្រុងស៊ីយ៉ូននិយាយទាក់ទងនឹងបទសរសើរថ្វាយដល់ព្រះជាម្ចាស់។ ដោយឡែកនៅក្នុងជំពូក១៣៧ ទីក្រុងស៊ីយ៉ូន ជាទីនឹករឭករបស់សាសន៍អ៊ីស្រាអែល។ ការនឹករឭកដល់ទីក្រុងនេះ បណ្តាលអោយគេយំជារៀងរាល់ថ្ងៃ។

ហេតុអ្វីបានជាសាសន៍អ៊ីស្រាអែល ត្រូវរសាត់ព្រាត់ទៅនៅប្រទេសបាប៊ីឡូនជាកន្លែងវេទនាដូច្នេះ? ព្រះគម្ពីរសម្តែងថា សាសន៍អ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះជាម្ចាស់។ ហោរាយេរេមាបានកត់ត្រារឿងនោះ។ លោកយេរេមាបានទាយថា កូនត្រូវគេយកបំបែកពីឪពុកម្តាយ ប្រពន្ធត្រូវបំបែកពីប្តី ប្តីត្រូវបំបែកពីប្រពន្ធ។ ព្រះជាម្ចាស់ប្រើលោក ដើម្បីប្រកាសសេចក្តីជំនុំជំរះដល់សាសន៍អ៊ីស្រាអែល ព្រោះគេបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះជាម្ចាស់។ លោកយេរេមាមានទឹកចិត្តដូចស្ត្រី។ ព្រះអង្គប្រើលោក ដើម្បីប្រកាសសេចក្តីជំនុំជំរះដល់ជាតិសាសន៍របស់លោក។ លោកយេរេមាបានកត់ត្រាទុករឿងនោះក្នុងគម្ពីរបរិទេវ។ បរិទេវ១:៨ ហោរាយេរេមាសម្តែងថា "ក្រុងយេរូសាឡិមបានធ្វើបាបយ៉ាងធ្ងន់ ហេតុនោះបានជាត្រូវត្រឡប់ដូចជារបស់ស្មោកគ្រោក អស់អ្នកដែលធ្លាប់លើកមុខនាង ឥឡូវគេមើលងាយវិញ ពីព្រោះគេបាន

ឃើញគេរខ្មាសនាងហើយ អើ នាងកំពុងតែថ្ងូរ ហើយបែរថយក្រោយ"។

ហេតុអ្វីបានជាសាសន៍អ៊ីស្រាអែលអង្គុយយំនៅមាត់ទន្លេស្រុកបាប៊ីឡូន? ពីព្រោះគេបានធ្វើបាបទាស់នឹងព្រះជាម្ចាស់។

យើងបានពាក់ព្យួរស៊ុងរបស់យើងនៅដើមចាក នាកណ្តាលស្រុកនោះ (ទំនុកដំកើង១៣៧:២)។

ដោយសារសាសន៍អ៊ីស្រាអែល រវល់តែយំនៅក្នុងសេចក្តីទុក្ខលំបាករបស់ខ្លួន គេមិនអាចច្រៀងបានទៀតទេ។ បទចម្រៀងទាំងអម្បាលមាណដែលគេធ្លាប់ច្រៀងបានរសាត់បាត់ចេញពីក្នុងចិត្តគេអស់ហើយ។ នៅក្នុងប្រទេសបាប៊ីឡូន គេមិនអាចច្រៀងសរសើរតម្កើងព្រះអង្គបាន ពីព្រោះទុក្ខវេទនាគ្របសង្កត់ចិត្តគេគ្រប់វិនាទី។ កាលគេនៅទីក្រុងយេរូសាឡិម ឬទីក្រុងស៊ីយ៉ូន គេបានច្រៀងបទសរសើរថ្វាយដល់ព្រះជាម្ចាស់។ ឥឡូវគេមានស៊ុង តែគេមិនអាចប្រើស៊ុង ដើម្បីច្រៀងសរសើរតម្កើងព្រះអង្គបានឡើយ។ គេព្យួរស៊ុងនៅលើដើមចាក។ សព្វថ្ងៃមានគ្រីស្ទបរិស័ទខ្លះ ព្យួរស៊ុងរបស់ខ្លួននៅលើដើមចាក។ ដោយសារទុក្ខលំបាកគ្របសង្កត់ ចម្រៀងសរសើរតម្កើងព្រះអង្គកំពុងរសាត់បាត់ពីក្នុងចិត្តគេ។ បងប្អូនជាគ្រីស្ទបរិស័ទអើយ តើបងប្អូនកំពុងបាត់បង់ចម្រៀងសរសើរតម្កើងព្រះអង្គពីក្នុងចិត្តអ្នកឬ? តើបងប្អូននឹកចាំពីសេចក្តីស្រឡាញ់ដើម ដែលមានចំពោះព្រះអង្គថ្ងៃដែលលោកអ្នកជឿព្រះអម្ចាស់យេស៊ូវគ្រីស្ទ

ជាអង្គសង្គ្រោះដែរឬទេ? បើលោកអ្នកភ្លេចហើយ អំណរនៃសេចក្តីសង្គ្រោះកំពុងរសាត់ចាត់ពីក្នុងចិត្តអ្នករាល់គ្នាដែរ។

បទពិសោធន៍យ៉ាងជូរចត់

ជ្រិតនៅទីនោះ ពួកអ្នកដែលនាំយើងទៅជាឈ្លើយ គេបង្ខំឱ្យយើងច្រៀងបទ គឺពួកអ្នកដែលបំផ្លាញយើង គេឱ្យយើងលេង ឱ្យគេបានអរសប្បាយដោយពាក្យថា ចូរច្រៀងបទ១របស់ក្រុងស៊ីយ៉ូនមកឱ្យយើងស្តាប់មើល (ទំនុកដំកើង១៣៧:៣)។

ពួកអ្នកស្រុកបាប៊ីឡូនធ្លាប់ឮថា ពីជំនាន់ដើមសាសន៍អ៊ីស្រាអែលពូកែច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់ណាស់។ មែនហើយ សាសន៍អ៊ីស្រាអែលជាសាសន៍ពូកែច្រៀងនិងពូកែសរសេរបទភ្លេង។ កាលសាសន៍អ៊ីស្រាអែលនៅមានឧត្តរបស់ខ្លួននៅឡើយ អ្នកទេសចរណ៍ធ្វើដំណើរទៅទីក្រុងយេរូសាឡិម ដើម្បីស្តាប់ការប្រគំតន្ត្រីដែលគេធ្វើឡើងសម្រាប់លើកសរសើរតម្កើងដល់ព្រះជាម្ចាស់ នៅព្រះវិហារទីក្រុងយេរូសាឡិម។ អ្នកទេសចរណ៍មិនដែលឃើញមានបទចម្រៀងណា មានសេចក្តីឧស្សាហ៍ណា មានតន្ត្រីករណា ដែលមានថ្វីដៃយ៉ាងចំណានក្នុងការច្រៀងសរសើរតម្កើងដល់ព្រះដ៏រស់ និងព្រះដ៏ពិតដូចសាសន៍អ៊ីស្រាអែលទេ។ បទចម្រៀងទាំងនោះ

រៀបរាប់ពីសេចក្តីព្រោសលោះរបស់ព្រះជាម្ចាស់ ព្រមទាំងសេចក្តីអត់ទោសនូវអំពើបាប ដល់រាស្ត្ររបស់ព្រះអង្គ។ គេមិនដែលឃើញមានជនជាតិណាចេះច្រៀងសរសើរតម្កើងព្រះ ព្រមទាំងលេងភ្លេងយ៉ាងប៉ិនប្រសប់យ៉ាងដូច្នោះទេ។ ឯបទចម្រៀងរបស់គេ មានន័យខ្លីមសារយ៉ាងជ្រាលជ្រៅ។ ដំណឹងល្អនេះបានឮចេញពីទីក្រុងយេរូសាឡិម សំដៅទៅដល់ទីកន្លែងឯទៀតៗ លើលោកយើងនេះ។ ព្រះមហាក្សត្រីយ៍នៅប្រទេសស៊ីបា បានធ្វើដំណើរយ៉ាងឆ្ងាយ ដើម្បីស្តាប់បទចម្រៀង និងភ្លេងសរសើរព្រះនៅទីក្រុងយេរូសាឡិម។ កាលព្រះនាងបានធ្វើដំណើរទៅដល់ ដំណឹងដែលឮទៅដល់ព្រះនាងតិចតួច ជាងហេតុការណ៍ដែលកើតឡើងជាក់ស្តែងនៅទីក្រុងយេរូសាឡិម។ សាសន៍អ៊ីស្រាអែលពូកែសរសេរចម្រៀងនិងបទភ្លេង។ នៅក្នុងប្រវត្តិសាស្ត្រ អ្នកដែលពូកែសរសេរចម្រៀងល្បីល្បាញនៅក្នុងពិភពលោក ជាសាសន៍អ៊ីស្រាអែល មានព្រះបាទដាវីឌ លោកម៉ូសេ លោកម៉ៃយ៉ាមបៀរ លោកអ័ហ្សាបខ លោកហ្សិត-ត្រៃស្ទ័រ លោកហ៊ីលិច-មិនដែលស្លន លោកហ្ជិច-ហ្គ័រស្ជិន លោកផល-វិតមិន លោកអ៊ីវិន-ប៊ីរលិន និងអ្នកសរសេរចម្រៀងបច្ចុប្បន្ននេះជាច្រើនរូបទៀត។ សាសន៍អ៊ីស្រាអែលពូកែសរសេរចម្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់។

ពេលនេះ ទីក្រុងយេរូសាឡិមក្លាយត្រឡប់ទៅជាគំនរសម្រាម។ អ្នកស្រុកអ៊ីស្រាអែលក្លាយត្រឡប់ទៅជាជនភៀសខ្លួន ដែលគេប្រើអោយជីកព្រែកបង្ហូរទឹកស្រោចស្រប់ផលិតផលកសិកម្មរបស់សាសន៍បាប៊ីឡូន។ សាសន៍អ៊ីស្រាអែលនាំគ្នាអង្គុយយំនៅមាត់ទន្លេស្រុកបាប៊ីឡូន។ ឯស៊ុងរបស់គេក៏ត្រូវព្យួរនៅលើដើមចាក។ សាសន៍

ចាប៊ីឡូន ព្រមទាំងជាតិសាសន៍ដទៃៗទៀត មើលងាយមើលថោកដល់សាសន៍អ៊ីស្រាអែល។

តែយើងនឹងច្រៀងបទនៃព្រះយេហូវ៉ា នៅក្នុងប្រទេសដទៃដូចម្តេចបាន (ទំនុកដំកើង១៣៧:៤)។

"តើយើងនឹងច្រៀងបទនៃព្រះយេហូវ៉ា នៅក្នុងប្រទេសដទៃដូចម្តេចបាន?" សាសន៍អ៊ីស្រាអែល មិនអាចច្រៀងចម្រៀងសរសើរព្រះនៅក្នុងប្រទេសដទៃបានទេ។ តាមពិត ព្រះជាម្ចាស់មិនបានបង្គាប់អោយសាសន៍នេះឈប់ច្រៀងយ៉ាងដូច្នោះឡើយ។ គេត្រូវច្រៀងសរសើរទ្រង់នៅក្រុងស៊ីយ៉ូន។

គ្រីស្ទបរិស័ទជារាស្ត្ររបស់ព្រះជាម្ចាស់ដែរ មានភារៈច្រៀងចម្រៀងសរសើរព្រះនៅក្នុងប្រទេសដទៃ។ សាសន៍អ៊ីស្រាអែលត្រូវច្រៀងបទសរសើរព្រះជាម្ចាស់នៅទីក្រុងស៊ីយ៉ូន។ គ្រីស្ទបរិស័ទមានគ្រប់ជាតិសាសន៍។ ទីណាដែលគេធ្វើដំណើរទៅ គេត្រូវច្រៀងចម្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់នៅទីនោះ។ ភូមិស្រុកណាដែលគេរស់នៅ គេត្រូវច្រៀងចម្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់។ ជនជាតិណាដែលជឿព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជនជាតិនោះមិនចាំបាច់ប្តូរផ្លាស់ពណ៌សម្បុរ មិនចាំបាច់ប្តូរផ្លាស់រូបកាយ មិនចាំបាច់ប្តូរផ្លាស់សម្លេង មិនចាំបាច់ប្តូរផ្លាស់នគររបស់ខ្លួនទេ គេនៅទីណាគេត្រូវច្រៀងសរសើរតម្កើងព្រះអង្គនៅទីនោះ។ ព្រះជាម្ចាស់ផ្តល់ចម្រៀងដល់គ្រីស្ទ

បរិស័ទគ្រប់រូប អោយចេះច្រៀងពីចម្រៀងនៃសេចក្តីសង្គ្រោះ ធ្វើជាទីបន្ទាល់ដល់មនុស្សលោក។

ប៉ុន្តែ ជាក់ស្តែងយើងឃើញថា គ្រីស្ទបរិស័ទចាត់បង់ចម្រៀងអំណររបស់ខ្លួនដូចសាសន៍អ៊ីស្រាអែលដែរ។ ឯមូលហេតុដែលធ្វើអោយគេចាត់ចម្រៀងអំណរនៅក្នុងចិត្ត មកពីមានឧបសគ្គបីយ៉ាង។

មួយ គ្រីស្ទបរិស័ទខ្លះមិនចេះច្រៀងតែម្តង ពីរ គ្រីស្ទបរិស័ទមានការអស់ទឹកចិត្ត អស់សេចក្តីក្លាហាន ចាំអោយគេឈប់ច្រៀងចម្រៀងសរសើរតម្កើងដល់ព្រះអង្គ។ ឯមូលហេតុទីបី ពីព្រោះគ្រីស្ទបរិស័ទបានប្រព្រឹត្តអំពើបាប មិនព្រមលន់តួអំពើបាបរបស់ខ្លួនចំពោះព្រះជាម្ចាស់។ អំពើបាបបានកៀបសង្កត់ចិត្តគំនិតរបស់គេមិនអោយមានអំណរក្នុងព្រះអង្គ។ ព្រះបាទដាវីឌប៉ុនប្រសប់និពន្ធចម្រៀង បទភ្លេង និងចូលចិត្តច្រៀងចម្រៀងសរសើរតម្កើងព្រះជាម្ចាស់ណាស់។ ពេលស្តេចអង្គនេះមិនបានលន់តួអំពើបាប ទ្រង់មិនអាចច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់បាន។ គម្ពីរទំនុកដំកើង៥១:១២ ព្រះបាទដាវីឌសម្តែងពីទឹកចិត្តរបស់ទ្រង់ថា "សូមឱ្យទូលបង្គំមានចិត្តរីករាយចំពោះសេចក្តីសង្គ្រោះនៃទ្រង់ឡើងវិញ ហើយទប់ទល់ទូលបង្គំ ដោយព្រះវិញ្ញាណដ៏សន្ធានៃទ្រង់"។ ឯទំនុកដំកើងជំពូក៣២ ស្តេចអង្គនេះចែងថា អំពើបាបដែលទ្រង់មិនបានលន់តួចំពោះព្រះជាម្ចាស់ ធ្វើអោយទ្រង់ចាត់សេចក្តីអំណរនៅក្នុងចិត្ត។ គ្រីស្ទបរិស័ទចាត់សេចក្តីអំណរ នាំអោយគេមិនបានច្រៀងសរសើរតម្កើងដល់ព្រះអង្គពេញដោយចេស្តា ពីព្រោះគេបានប្រព្រឹត្តអំពើបាប ហើយមិនបានលន់តួនៅចំពោះព្រះជាម្ចាស់។

ចុះព្រះអម្ចាស់យេស៊ូវគ្រីស្ទវិញ តើទ្រង់រងទុក្ខមកពីព្រះអង្គមានចាបឬ? អេសាយជំពូក៥៣:៤សម្តែងថា "ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងជាពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា"។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទរងទុក្ខមិនមែនដោយព្រោះអំពើចាបរបស់ទ្រង់ផ្ទាល់ទេ។ ព្រះអង្គរងទុក្ខដោយសារអំពើចាបរបស់យើងរាល់គ្នាវិញទេតើ។ ហេតុអ្វីបានជាសាសន៍អ៊ីស្រាអែលនាំគ្នាអង្គុយយំនៅមាត់ទន្លេស្រុកចាប៊ីឡូន? គេចាត់ចម្រៀងច្រៀងសរសើរតម្កើងព្រះអង្គ ពីព្រោះគេបានប្រព្រឹត្តអំពើចាបទាស់នឹងព្រះជាម្ចាស់។

បទពិសោធន៍យ៉ាងរំភើប

៥ឱក្រុងយេរូសាឡិមអើយ បើសិនជាខ្ញុំភ្លេចឯង នោះសូមឱ្យដៃស្តាំខ្ញុំភ្លេចថ្វីដៃទៅផង ៦បើសិនជាខ្ញុំមិនរឭកដល់ឯង គឺបើខ្ញុំមិនចូលចិត្តនឹងក្រុងយេរូសាឡិម ជាជាងសេចក្តីអំណរយ៉ាងសំខាន់របស់ខ្ញុំ នោះសូមឱ្យអណ្តាតខ្ញុំជាប់នៅក្រអូមមាត់ចុះ (ទំនុកដំកើង១៣៧:៥-៦)។

ទោះបីសាសន៍អ៊ីស្រាអែលត្រូវគេបង្ខិតបង្ខំអោយធ្វើការយ៉ាងទម្ងន់ គេបំបែកគ្រួសារអោយនៅដាច់ដោយឡែកនៅក្នុងភូមិស្រុករបស់អ្នកជទៃក៏ដោយ សេចក្តីសង្ឃឹមរបស់គេនៅតែមានជានិច្ចថា នឹងបានឃើញទីក្រុងយេរូសាឡិម។ សេចក្តីសង្ឃឹមរបស់គេ ស្ថិតនៅលើការកោតខ្លាចដល់ព្រះជាម្ចាស់។ គេនិយាយថា ឱក្រុងយេរូសាឡិមអើយ... "បើសិនជាខ្ញុំភ្លេចឯង នោះសូមឱ្យដៃស្តាំខ្ញុំភ្លេចថ្វីដៃទៅផង"។ ម្យ៉ាងទៀតសាសន៍អ៊ីស្រាអែលមានសង្ឃឹមថា "...បើខ្ញុំមិនចូលចិត្តនឹងក្រុងយេរូសាឡិម នោះសូមឱ្យអណ្តាតខ្ញុំជាប់នៅក្រអូមមាត់ខ្ញុំចុះ"។ កំពុងតែឆ្លងកាត់ទុក្ខលំបាក រាស្ត្ររបស់ព្រះជាម្ចាស់នៅមានសេចក្តីសង្ឃឹមលើព្រះជាម្ចាស់ឥតមានអ្វីធ្វើអោយគេរង្គើបានឡើយ។

ឱព្រះយេហូវ៉ាអើយ សូមទ្រង់នឹកចាំពីពួកជនជាតិអេដំមថា នៅថ្ងៃលំបាកនៃក្រុងយេរូសាឡិម នោះគេបានស្រែកថា ចូររំលំវា ចូររំលំវាទៅ រហូតដល់ឫសជញ្ជាំងផង (ទំនុកដំកើង១៣៧:៧)។

ក្នុងប្រវត្តិសាស្ត្រ សាសន៍អេដំមជាសត្រូវសួរពូជរបស់សាសន៍អ៊ីស្រាអែល។ នៅពេលសាសន៍អេដំមឃើញសាសន៍អ៊ីស្រាអែលដួលយ៉ាងដូច្នោះ គេនាំគ្នាពន្យុះសាសន៍បាប៊ីឡូនអោយបំផ្លាញសាសន៍អ៊ីស្រាអែលចោលតែម្តងទៅ។ ចំណែកសាសន៍អ៊ីស្រាអែលវិញ បានអធិស្ឋានសូមអោយព្រះជាម្ចាស់ដាក់បណ្តាសាដល់សាសន៍អេដំម។ នៅក្នុងករណីនេះ សាសន៍អ៊ីស្រាអែលសូមអោយព្រះជាម្ចាស់រកយុត្តិធម៌អោយខ្លួន

ពេលដែលសាសន៍អេដំមវីកវាយសប្បាយចិត្ត ដោយឃើញគេកំពុងតែដួលយ៉ាងដូច្នេះ។ សាសន៍អ៊ីស្រាអែលមានសិទ្ធិទូលសូមអោយព្រះជាម្ចាស់រកយុត្តិធម៌អោយខ្លួន។

ចុះចំណែកគ្រីស្ទបរិស័ទវិញ តើយើងត្រូវអធិស្ឋានទូលសូមដល់ព្រះជាម្ចាស់ អោយបំផ្លិចបំផ្លាញដល់សត្រូវរបស់ខ្លួនដែរឬទេ? គ្រីស្ទបរិស័ទគ្មានសិទ្ធិអធិស្ឋានទូលសូមអោយព្រះជាម្ចាស់បំផ្លាញសត្រូវរបស់ខ្លួនជាដាច់ខាត។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទ មានបន្ទូលដោយព្រះឱស្ឋទ្រង់ពីលើឈើឆ្កាងមកថា "...ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ គេក៏នាំគ្នាធ្វើឆ្នោតចាប់ព្រះពស្ត្រទ្រង់ចែកគ្នា" (លូកា២៣:៣៤)។ តើព្រះអម្ចាស់ទ្រង់រាប់អ្នកដែលឆ្កាងព្រះអង្គ និងអ្នកដែលស្រែកសន្ធាប់គាំទ្រ អោយគេឆ្កាងទ្រង់ទៅថា គេគ្មានអំពើបាបឬ? មិនមែនទេ! ជនទាំងនោះមានបាបយ៉ាងក្រាស់។ ព្រះអង្គអធិស្ឋានសូមដល់ព្រះវរបិតាថា បើគេបែរមកទទួលជឿដល់ព្រះអង្គវិញ សូមទ្រង់អត់ទោសដល់អ្នកដែលបានឆ្កាងទ្រង់នេះផង។ ពេលដែលគេឆ្កាងព្រះអម្ចាស់យេស៊ូវគ្រីស្ទ លោកសូលអ្នកស្រុកតាសើសបាននៅទីនោះដែរ។ ពេលក្រោយមកទៀត លោកសូលអ្នកស្រុកតាសើសបានទូលសូមអោយព្រះអម្ចាស់យេស៊ូវគ្រីស្ទ អត់ទោសបាបដល់លោក។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានអត់ទោសបាប ដល់លោកសូលអ្នកស្រុកតាសើស។

ម្យ៉ាងវិញទៀត លោកស្ទេផានបានអធិស្ឋានសូមដល់ព្រះជាម្ចាស់ថា "...ឱព្រះអម្ចាស់អើយ សូមកុំរាប់បាបនេះដល់គេឡើយ កាលគាត់បានពោលដូច្នោះហើយ នោះក៏ដេកលក់ទៅ ឯសុលក៏យល់ព្រមក្នុងការសំឡាប់គាត់ដែរ" (កិច្ចការ៧:៦០)។

លោកស្មៀនជានសូមអោយព្រះជាម្ចាស់ទ្រង់អត់ទោសដល់គេផង ដ្បិតលោកស្តាប់បង្គាប់ដល់ព្រះជាម្ចាស់ មិនសូមអោយព្រះជាម្ចាស់បំផ្លិចបំផ្លាញដល់សត្រូវរបស់លោកទេ។ សាវ័កប៉ុលដាស់តឿនដល់គ្រីស្ទបរិស័ទក្នុងគម្ពីររ៉ូម១២:១៩ថា "ឱពួកស្ងួនភ្ងាអើយ កុំឱ្យសងសឹកឡើយ ចូរថយចេញពីសេចក្តីកំហឹងទៅ ដ្បិតមានសេចក្តីចែងទុកមកថា "ព្រះអម្ចាស់ ទ្រង់មានបន្ទូលថា ការសងសឹកនោះស្រេចនឹងអញ អញនឹងសងដល់គេ"។ ព្រះជាម្ចាស់បង្គាប់ដល់គ្រីស្ទបរិស័ទគ្រប់រូប មិនត្រូវសងសឹកចំពោះសត្រូវរបស់ខ្លួនជាដាច់ខាត។ ព្រះជាម្ចាស់មានផែនការគ្រប់គ្រាន់ សម្រាប់សងសឹកដល់សត្រូវរបស់គ្រីស្ទបរិស័ទ។ កាលណាគ្រីស្ទបរិស័ទធ្វើការសងសឹកខ្លួនឯង គ្រីស្ទបរិស័ទកំពុងបញ្ជាក់ភាវៈថាខ្លួនឈប់ទុកចិត្តដល់ព្រះជាម្ចាស់ ថាទ្រង់ពិតជាមានសមត្ថភាព អាចដោះស្រាយរឿងរបស់ខ្លួន។ គ្រីស្ទបរិស័ទត្រូវទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងរកយុត្តិធម៌ដល់ខ្លួន។ យុត្តិធម៌ពិតជាមាន បើគ្រីស្ទបរិស័ទទុកចិត្តដល់ព្រះជាម្ចាស់ថា ទ្រង់នឹងដោះស្រាយរឿងនោះអោយយើង។ ព្រះជាម្ចាស់មានភាពយុត្តិធម៌ ព្រះអង្គល្អ ទ្រង់សប្បុរស ព្រះអង្គមិនដែលបណ្តោយអោយមនុស្សអាក្រក់យកជ័យជំនះ លើរាស្ត្ររបស់ព្រះអង្គបានជាដាច់ខាត។

ឱកូនស្រីនៃបាប៊ីឡូនអើយ ឯងនឹងត្រូវបំផ្លាញហើយ សប្បាយហើយ អ្នកណាដែលសងដល់ឯង តាមការដែលឯងបានប្រព្រឹត្តនឹងយើង (ទំនុកដំកើង១៣៧:៨)។

ព្រះបន្ទូលខាងលើស្ថិតនៅក្រោមច្បាប់មួយហៅថា ច្បាប់ចងពៀរ។ គ្រីស្ត បរិស័ទគ្រប់រូបស្ថិតនៅក្រោមច្បាប់ចងពៀរនេះដែរ។ ព្រះបន្ទូលគម្ពីរកាឡាទី៦:៧ចែងថា "កុំឱ្យច្រឡំឡើយ នឹងបញ្ឆោតព្រះមិនបានទេ ដ្បិតពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ"។ ម្យ៉ាងទៀតព្រះអម្ចាស់យេស៊ូវមានបន្ទូលពីព្រះវិស្ដទ្រង់ផ្ដាល់ដែរថា "...ចូរសឹកដាវអ្នកទៅក្នុងស្រោមវិញទៅ ដ្បិតអស់អ្នកដែលយកដាវ នោះត្រូវស្លាប់ដោយដាវដែរ" (ម៉ាថាយ២៦:៥២)។ ឥឡូវនេះ យើងឈានមកដល់ខមួយដែលពិចារណាយល់បន្ដិចនៅក្នុងជំពូក១៣៧។

សប្បាយហើយ អ្នកណាដែលនឹងចាប់កូនតូចរបស់ឯង ទៅចោក នឹងថ្មផង (ទំនុកដំកើង១៣៧:៩)។

សាសន៍អ៊ីស្រាអែល ស្ថិតនៅក្រោមការជិះជាន់ពីសំណាក់សាសន៍បាប៊ីឡូន។ គេកៀរយកអ្នកស្រុកនេះទៅអោយជីកព្រែក ព្រមទាំងធ្វើការយ៉ាងទម្ងន់ផ្សេង១ទៀតជាច្រើន។ ដោយសារមូលហេតុនោះ សាសន៍អ៊ីស្រាអែលមានភាពតោកយ៉ាក ក្ររហេមរហាម និងមានសណ្ឋានថោកទាបនៅក្នុងជីវិតរបស់ខ្លួនយ៉ាងខ្លាំង។ ប្ដីខ្លះឃើញទាហានសាសន៍បាប៊ីឡូនរំលោភប្រពន្ធខ្លួននៅនឹងភ្នែក។ កូនខ្លះមើលគេសម្លាប់ឪពុកម្ដាយនៅមុខខ្លួន ហើយពោលថា "មិនមែនពុកខ្ញុំទេ គាត់ជាខ្មាំង"។ ម្ដាយខ្លះកំពុងតែបំបៅកូនស្រាប់តែទាហានសាសន៍បាប៊ីឡូន ចូលមកចាប់កូនរបស់ខ្លួនទៅចោកក្បាលផ្ដប់នឹង

ថ្មដា។ កូនង៉ែតខ្លះទៀតត្រូវគេចោះទៅលើ រួចហើយយកកាំបិតជំពុះទុងទ្រពីក្រោមនៅមុខម្តាយ។ មនុស្សលោកពូកែធ្វើទារុណកម្មដល់មនុស្សគ្នាឯងណាស់។

អរគុណដល់ព្រះជាម្ចាស់ បើព្រះជាម្ចាស់គ្មានសេចក្តីមេត្តាករុណាចំពោះមនុស្សលោកទេ មនុស្សលោកសម្លាប់គ្នាឯងដូចសត្វធាតុអស់បាត់ទៅហើយ។ ព្រះជាម្ចាស់ប្រទានព្រះយេស៊ូវគ្រីស្ទអោយមកសុគតជំនួសមនុស្សមានបាប ដើម្បីប្រោសមនុស្សអោយបានល្អប្រសើរដូចកាលដែលព្រះអម្ចាស់បង្កើតពីដំបូងមក។ បច្ចុប្បន្ននេះព្រះអង្គនៅតែសម្តែងសេចក្តីមេត្តាករុណា និងសេចក្តីសប្បុរសរបស់ទ្រង់។ បើលោកអ្នកចង់ទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះ លោកអ្នកមានលទ្ធភាពអាចទទួលព្រះអង្គបាន។ ប៉ុន្តែសូមជ្រាបថា បើលោកអ្នកមិនព្រមទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះទេ គ្មានមធ្យោបាយណាលោកអ្នកអាចគេចរួចពីសេចក្តីជំនុំជំរះ ដែលត្រូវកើតឡើង ដូចមនុស្សលោកបានធ្វើទារុណកម្មគ្នាទេវិញទៅមក ដូចបានរៀបរាប់នៅក្នុងខគម្ពីរនេះទេ។

គម្ពីរទំនុកដំកើងជំពូក១៣៧ពិបាកយល់ តែមានអាថ៌កំបាំងដែលព្រះជាម្ចាស់បង្កប់ទុកសម្រាប់យើង។ យើងត្រូវឈប់ ឈរ រួចហើយឈាន ដើម្បីយល់ពីអាថ៌កំបាំងដែលបង្កប់នៅក្នុងជំពូកនេះ។

យើងស្វែងការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះជាមួយនឹងព្រះយេស៊ូវជាមិនខាន!"